**UNITED NATIONS**
CAMBODIA OFFICE OF THE
HIGH COMMISSIONER FOR HUMAN RIGHTS

**NATIONS UNIES**
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for Human Rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

COHCHR


# សេចក្តីថ្លែងការណ៍របស់ លោក ភីថ័រ លយប្រែកត៍
# តំណាងពិសេសរបស់លោកអគ្គលេខាធិការ អ.ស.ប
# ទទួលបន្ទុកសិទ្ធិមនុស្ស ប្រចាំប្រទេសកម្ពុជា

លោក ភីថ័រ លយប្រែកត៍ តំណាងពិសេសនៃលោកអគ្គលេខាធិការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជាបានសំដែងនូវការព្រួយបារម្ភចំពោះការវិវត្តន៍ថ្មីបំផុត ក្នុងការកាត់ទោសជនជាប់ចោទពីររូប គឺឈ្មោះ ប៊ិន សំណាង និង សុខ សំអឿន ក្នុងអំពើឃាតកម្មលើរូបលោក ជា វិជ្ជា ប្រធានសហជីពកម្មករ កាលពីខែមករា ឆ្នាំ២០០៤ កន្លងទៅនេះ ។ កាលពីថ្ងៃទី០១ ខែកក្កដា សាលាឧទ្ធរណ៍បានច្រានចោលសេចក្តីសំរេចរបស់ចៅក្រមតុលាការដំបូង ដោយលើកលែងការចោទប្រកាន់ព្រោះគ្មានភស្តុតាងគ្រប់គ្រាន់ ហើយបានបញ្ជូនករណីរឿងនោះ ត្រឡប់មកតុលាការរាជធានីភ្នំពេញវិញ ដើម្បីធ្វើការស៊ើបអង្កេតលើករណីឃាតកម្មនេះបន្ថែមទៀត ។

លោកតំណាងពិសេសនឹងបន្តការយកចិត្តទុកដាក់យ៉ាងជិតដល់ចំពោះករណីនេះ ដោយសង្កេតឃើញមានភាពមិនប្រក្រតីជាច្រើនខាងនីតិវិធីនៅក្នុងការស៊ើបអង្កេត និងការចោទប្រកាន់ ។ ក្នុងនេះរួមមានការចាប់ ខ្លួនជនជាប់ចោទដោយគ្មានដីកាពីតុលាការ ការខ្វះភស្តុតាងដាក់បន្ទុកលើជនជាប់ចោទទាំងពីររូប ចំលើយសារភាពតាំងពីដំបូងរបស់ជនជាប់ចោទម្នាក់ដែលគេចោទថា ការឆ្លើយសារភាពនេះធ្វើឡើងដោយការបង្ខិតបង្ខំ បន្ទាប់ពីខ្លួនត្រូវគេវាយដំបង្ខំឱ្យឆ្លើយ ការបង្ហាញពីល្បិចកិច្ចកល ការចោទប្រកាន់ថាមានការជ្រៀតជ្រែកពីអង្គនីតិប្រតិបត្តិទៅក្នុងការងាររបស់ចៅក្រមស៊ើបអង្កេត (លោក ហ៊ីង ធីរិទ្ធិ ) ដែលបានលើកលែងការចោទប្រកាន់ដោយសារគ្មានភស្តុតាងគ្រប់គ្រាន់ ។ ការចាត់វិធានការខាងវិន័យទៅលើចៅក្រម ដែលធ្វើឡើងបន្ទាប់ពីចៅក្រមរូបនោះបានចេញដីកាលើកលែងចោទប្រកាន់ និង ការប្រកាសបន្ទាប់មកទៀតអំពីការផ្លាស់ប្តូរចៅក្រមរូបនេះដោយបង្ខំឱ្យទៅធ្វើការនៅកន្លែងដែលឆ្ងាយដាច់ស្រយ៉ាល គឺខេត្តស្ទឹងត្រែង នៅមុនពេលបើកសវនាការនៅសាលាឧទ្ធរណ៍ ។

លោក ជា វិជ្ជា ត្រូវបានគេបាញ់សំលាប់នៅកណ្តាលក្រុងភ្នំពេញ កាលពីព្រឹកថ្ងៃទី២២ ខែមករា ដែលនេះគឺជាអំពើឃាតកម្មមួយក្នុងចំណោមអំពើឃាតកម្មកើតមានជាហូរហែរកន្លងមក ដែលមានលក្ខណៈជាការស៊ីឈ្នួលសំលាប់មនុស្ស និងការប៉ុនប៉ងធ្វើឃាតលើឥស្សរជនសំខាន់ៗ ក្នុងប្រទេសកម្ពុជា នៅក្នុងរយៈពេល១៨ ខែកន្លងមកនេះ ។ ការសំរេចផ្តន្ទាទោសបានធ្វើនៅក្នុងករឿងមួយចំនួន ប៉ុន្តែនៅមានបញ្ហាជាច្រើនដែលបានចោទឡើង


#16A, Mao Tse Tuong Blvd, Sangkat Tonle Bassac, Khan Chamcar Mon, Phnom Penh, Cambodia.
Tel: (855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: (855) 23 212 579 or 213 587 E-mail: cohchr@online.com.kh
ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា លេខ ១៦A មហាវិថី ម៉ៅ សេទុង សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន ភ្នំពេញ កម្ពុជា
ទូរស័ព្ទលេខ: ៨៥៥-២៣ ៩៨៧ ៦៧១ / ៩៨៧ ៦៧២ / ៩៩៣ ៥៩០ / ៩៩៣ ៥៩១ / ឬ ២១៦ ៣៤២ ទូរសារ: ៨៥៥-២៣ ២១២ ៥៧៩ ឬ ២១៣ ៥៨៧

ទាក់ទងនឹងការស៊ើបអង្កេត ហើយនិងការកាត់ទោសមិនបានគោរពទៅតាមការធានាជាអប្បរិមាចំពោះការជំនុំជំរះក្តីឱ្យបានប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ដែលធ្វើឱ្យមានការមិនទុកចិត្តអំពីការសំរេចទោសក្នុងករណីរឿងមួយចំនួន ។ មានករណីរឿងជាច្រើន ដែលស្វែងរកជនសង្ស័យមិនឃើញ ។ ក្នុងករណីរឿងផ្សេងទៀតមានសំណួរចោទឡើងដោយសង្ស័យថាមានភាពលំអៀងនៅក្នុងការស៊ើបអង្កេត ការគ្មានភស្តុតាងណាផ្សេងក្រៅតែពីចំលើយសារភាព ការមិនទទួលយកនូវភស្តុតាងដោះបន្ទុក ដូចជាការផ្តល់សក្ខីកម្មថានៅពេលកើតហេតុជនជាប់ចោទមិនស្ថិតនៅកន្លែងកើតហេតុទេ (alibi) និងការខកខានដែលមិនគួរកើតមានក្នុងការស្វែងរកអ្នកដែលបញ្ជាឱ្យអ្នកស៊ីឈ្នួលសំលាប់ ។ លោក ភីធ័រ លយប្រែកត៍ បានអធិប្បាយថា លោកមានការព្រួយបារម្ភជាខ្លាំងដោយសង្កេតឃើញមានការមិនសូវយកចិត្តទុកចំពោះសេចក្តីអំពាវនាវរបស់លោកឧត្តមស្នងការ អ.ស.ប ស្តីទីទទួលបន្ទុកសិទ្ធិមនុស្សដែលបានធ្វើឡើងកាលពីខែមករា កន្លងទៅនេះ ដែលសុំឱ្យមាន "ការស៊ើបអង្កេតឱ្យបានពេញលេញ និងមិនលំអៀងធ្វើឡើងជាសាធារណៈ ដើម្បីស្វែងរកឱ្យឃើញទាំងអ្នកដែលទទួលខុសត្រូវដោយផ្ទាល់ចំពោះការសំលាប់ លោក ជា វិជ្ជា ក៏ដូចជាអ្នកដែលបញ្ជាឱ្យសំលាប់ផងដែរ" ។

"បញ្ហានិទណ្ឌភាព គឺជាបញ្ហាស្នូលសំខាន់ជាងគេ ចំពោះសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ។ បញ្ហានេះមិនអាចដោះស្រាយដោយគ្រាន់តែធ្វើការចាប់ខ្លួនមនុស្ស នៅក្នុងករណីរឿងឧក្រិដ្ឋកម្មធំៗ ដោយមិនគិតគូពីបញ្ហាភស្តុតាងនោះទេ ។ រាល់ការស៊ើបអង្កេតទាំងអស់ត្រូវធ្វើឡើងឱ្យបានពេញលេញ និងមិនលំអៀង ហើយនីតិវិធីរបស់តុលាការត្រូវតែអនុវត្តដោយគោរពយ៉ាងត្រឹមត្រូវចំពោះសិទ្ធិខាងនីតិវិធីរបស់ជនជាប់ចោទ ដែលចែងធានានៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងសន្ធិសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស ដែលប្រទេសកម្ពុជាជាភាគីហត្ថលេខីមួយដែរ ។ នៅក្នុងករណីរឿងរបស់លោក ជា វិជ្ជា មានសញ្ញាបង្ហាញយ៉ាងច្រើនថា ជនជាប់ចោទត្រូវបានគេជ្រើសរើសឱ្យមកទទួលនូវការចោទទោស ដោយមិនគិតពីភស្តុតាងដែលបានផ្តល់ឱ្យឡើយ ។ លោក លយប្រែកត៍ បានថ្លែងថា ការមិនសូវជឿថា ជនទាំងពីររូបខាងលើនេះគឺជាអ្នកទទួលខុសត្រូវក្នុងឧក្រិដ្ឋកម្មនេះ ធ្វើឱ្យសាធារណៈជនបាត់បង់ជំនឿទុកចិត្តលើការគ្រប់គ្រងប្រព័ន្ធតុលាការ " ។

ការិយាល័យឧត្តមស្នងការ អ.ស.ប ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជានឹងបន្តឃ្លាំមើលកិច្ចដំណើរការស៊ើបអង្កេត និង ការជំនុំជំរះក្តីរបស់តុលាការនៅក្នុងករណីរឿងនេះតទៅទៀត ។

ធ្វើនៅថ្ងៃទី ៨ ខែកក្កដា ឆ្នាំ២០០៤

*ពត៌មានបន្ថែម សូមទាក់ទង លោកស្រី Saku Akmeemana by: 012822274*